00236247

D99/3/30

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | ៖ | ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០២) |
| **កាលបរិច្ឆេទនៃឯកសារ** | ៖ | ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន** | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម** | ៖ | អង់គ្លេស |
| **ប្រភេទឯកសារ** | ៖ | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / NOV / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Auy

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា
## នៅនឹងសំណើរួមរបស់មេធាវីការពារក្តី ស្នើសុំចូលអន្តរាគមន៍នៅក្នុងបណ្តឹងឧទ្ធរណ៍

---

**<u>បញ្ជូនដោយ៖</u>**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

លោក Alex BATES

**ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / NOV / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Auy

**<u>ចែកចាយជូន៖</u>**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម ន័យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច៖**

លោក ការ សាវុត្ថ

លោក François ROUX

**មេធាវីការពារក្តីរបស់អ្នកដាក់ពាក្យ ដែលមិនមែនជាភាគី៖**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក ផាត់ ពៅសៀង

កញ្ញា Diana ELLIS

លោក ស សូវ៉ាន

លោក Jacques VERGÈS

00236248

D99/3/30

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០២)

## ១.ចម្លើយតប

១. អ្នកដាក់ពាក្យសុំ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ("អ្នកដាក់ពាក្យសុំ") មិនមែនជាភាគីនៅក្នុងបណ្តឹងឧទ្ធរណ៍នេះទេ។ ពួកគេក៏មិនមែនជាភាគី ឬ អ្នកដែលត្រូវចោទប្រកាន់នៅក្នុងសំណុំរឿងលេខ ០០១ ដែលត្រូវបានគេប្តឹងឧទ្ធរណ៍នេះដែរ។ ក៏ប៉ុន្តែពួកគេបានដាក់ពាក្យសុំមួយ ("ពាក្យសុំ") ស្វែងរកសុំធ្វើអន្តរាគមន៍នៅក្នុងដំណើរការនីតិវិធីទាំងនេះ ដើម្បីដាក់សារណាស្តីពីការអនុវត្តន៍នៃសហកម្មឧក្រិដ្ឋកម្មរួមនៅចំពោះមុខតុលាការនេះ[1] ។ ពួកគេបានទាមទារថា ផលប្រយោជន៍ជាលទ្ធផលដែលកើតចេញមកពីបណ្តឹងឧទ្ធរណ៍នេះគឺ ជាដំណោះស្រាយសម្រាប់បញ្ហាសហកម្មឧក្រិដ្ឋកម្មរួមសម្រាប់ពេលបច្ចុប្បន្ននេះ ដែលបើតាមពួកគេថា វាមុខជានឹងមានផលប៉ះពាល់ទៅដល់កិច្ចស៊ើបសួរប្រឆាំងនឹងរូបពួកគេ ដែលស្ថិតនៅក្នុងសំណុំរឿងលេខ០០២[2] ដាច់ដោយឡែកពីនេះ ។

២. មានសំណើដូចគ្នានេះបេះបិទមួយ ដែលធ្វើឡើងដោយ អៀង សារី ត្រូវបានអង្គបុរេជំនុំជម្រះបដិសេធចោលក្នុងពេលថ្មីៗនេះ ។ ក្នុងការបដិសេធនេះ អង្គបុរេជំនុំជម្រះ បានសម្រេចថា អៀង សារី មិនមានតួនាទីអ្វីដើម្បីធ្វើអន្តរាគមន៍នៅក្នុងបណ្តឹងឧទ្ធរណ៍នេះទេ ដោយសារគាត់មិនមែនជាភាគីនៅក្នុងសំណុំរឿងលេខ០០១ ដែលពាក់ព័ន្ធតែជាមួយ ឌុច ប៉ុណ្ណោះ[3] ។ អង្គបុរេជំនុំជម្រះបានរកឃើញថា ទាំងនៅក្នុងវិធានផ្ទៃក្នុងក្តី ទាំងនៅក្នុងក្រមនីតិវិធីព្រហ្ម

---

[1] *ករណីរបស់ ឌុច,* សំណើរួមជាបន្ទាន់របស់មេធាវីការពារក្តីដែលស្នើសុំឲ្យធ្វើអន្តរាគមន៍នៅក្នុងពាក្យសុំអំពីទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួមដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ការិយាល័យសហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាដំណោះស្រាយលើ ឌុច, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២), ឯកសារលេខ D99/3/26 ចុះថ្ងៃទី២៨ តុលា ២០០៨ [ដែលបន្ទាប់ពីនេះទៅហៅថា ពាក្យសុំ] ។

[2] ពាក្យសុំ, ត្រង់ទំព័រ២១ ។

[3] *ករណីរបស់ ឌុច,* សេចក្តីសម្រេចលើពាក្យសុំរបស់លោក អៀង សារី សុំជាអ្នកដែលមិនមែនជាភាគីនៃរឿងក្តី, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ-០២), ឯកសារតុលាការលេខ D99/3/16, ចុះថ្ងៃទី១៤ តុលា ២០០៨, កថាខណ្ឌទី ៣ និង ៦ ។

ទណ្ឌកម្មជាក្តី សុទ្ធតែមិនបានទុកលទ្ធភាពឲ្យភាគីទីបីណាមួយធ្វើអន្តរាគមន៍នៅក្នុងបណ្តឹងឧទ្ធរណ៍ និងឲ្យដាក់សារណានោះទេ[4] ។

៣. ករណីរបស់អ្នកដាក់ពាក្យសុំ មានលក្ខណៈដូចគ្នាបះបិទទៅនឹងពាក្យសុំរបស់ អៀង សារី ដែរ។ ដើមបណ្តឹងឧទ្ធរណ៍ និងអៀង សារី កំពុងត្រូវបានស៊ើបសួរតែក្នុងសំណុំរឿងលេខ០០២ ប៉ុណ្ណោះ ។ ពួកគេមិនមែនជាភាគី និងមិនមានសិទ្ធិក្នុងសំណុំរឿងលេខ ០០១ ទេ ។ អាស្រ័យហេតុនេះ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ក្នុងករណីរបស់ អៀង សារី ត្រូវតែអនុវត្តដោយផ្ទាល់នៅក្នុងករណីរបស់អ្នកដាក់ពាក្យសុំផងដែរ ។ ដើមបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញឲ្យឃើញពីភាពខុសគ្នានៃករណីរបស់ខ្លួន និងករណីរបស់ អៀង សារី ដូចម្តេចឡើយ។ ពួកគេក៏មិនបានបញ្ជាក់ការពិតអំពីការផ្លាស់ប្តូរកាលៈទេសៈណាមួយ គឺមានតិចតួចណាស់ដែលថា មានការអនុញ្ញាតឲ្យមានការគិតគូរ ពីការសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅក្នុងករណីរបស់ អៀង សារី ឡើយ ។

៤. អ្វីដែលមានជាប់មកជាមួយនឹងតុលាការ ដូចជាអ.វ.ត.ក នេះជាដើម ដែលថា សេចក្តីសម្រេចនៅក្នុងករណីមួយ ស្តីពីបញ្ហាច្បាប់ នឹងជាការនាំផ្លូវដល់តុលាការនេះសម្រាប់ករណីផ្សេងៗទៀតដែលមានលក្ខណៈស្រដៀងគ្នានេះសម្រាប់អនាគត បើសិនគ្មានការកំណត់ពីកាលៈទេសៈថ្មី ឬសេចក្តីអះអាងមិនត្រូវបានគេលើកឡើងទេនោះ ។ ប៉ុន្តែ គេមិនអនុវត្តតាមឡើយ បើសិនជនត្រូវចោទមានសិទ្ធិធ្វើអន្តរាគមន៍តាមរយៈការដាក់ជូនទស្សនៈរបស់ខ្លួន នៅក្នុងសំណុំរឿងមួយដែលខ្លួនមិនមែនជាភាគីនោះ[5] ។

---

[4] សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តី សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/ អ.វ.ត.ក-ក.ស.ច.ស (អបជ ០២), ឯកសារតុលាការ លេខ D99/3/19, ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨, កថាខ័ណ្ឌទី ៩ ។

[5] សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្តីពីការអនុវត្តន៍ទ្រឹស្តី សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ

D99/3/30



៥. បណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងបទចោទទាំងឡាយដែល ឌុច តែម្នាក់ឯងនឹងត្រូវបញ្ជូនទៅធ្វើការជំនុំជម្រះ ។ ហេតុដូច្នេះ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ នឹងមិនអនុវត្តដោយត្រង់ៗចំពោះអ្នកដាក់ពាក្យសុំនានាដូចជា អៀង សារី ជាដើម ដែលនឹងនៅតែមានលទ្ធភាពក្នុងការជំទាស់នឹងការអនុវត្តន៍នូវសហកម្មឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿងលេខ ០០២ ដែលពួកខ្លួនគឺជាភាគីនៅក្នុងសំណុំរឿងនោះ[6] ។

## ២. សំណើ

៦. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គបុរេជំនុំជម្រះបដិសេធសំណើនេះចោលតាំងពីដើមដំបូង ព្រោះថានៅក្នុងករណីណាក៏ដោយ មានលក្ខណៈជាន់គ្នាពីរដង ហើយគ្មានន័យខ្លឹមសារទេ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**



**លោក យ៉េត ចរិយា**
**សហព្រះរាជអាជ្ញារង**

**លោក** Robert PETIT
**សហព្រះរាជអាជ្ញា**

---

០០១/១៨-០៧-២០០៧/ អ.វ.ត.ក-ក.ស.ច.ស (អបជ ០២), ឯកសារតុលាការ លេខ D99/3/19, ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨, កថាខ័ណ្ឌទី ១៤ ។

[6] សេចក្ដីសម្រេចលើសំណើរបស់លោក អៀង សារី សុំដាក់អំណះអំណាងស្ដីពីការអនុវត្តន៍ទ្រឹស្ដី សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/ អ.វ.ត.ក-ក.ស.ច.ស (អបជ ០២), ឯកសារតុលាការ លេខ D99/3/19, ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨, កថាខ័ណ្ឌទី ១២ ។